**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ និង រដ្ឋមន្ត្រីរដ្ឋលេខាធិការ នៃ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៥៩ អនក្រ**

**ស្តីពីការប្តូរចនាសម្ព័ន្ធរដ្ឋបាល ក្រុងកែប ពីថ្នាក់ស្រុកមកជាថ្នាក់ក្រុង**

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញច្បាប់ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩២ និង អនុក្រឹត្យ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩២ នៃអតីតរដ្ឋកម្ពុជាស្តីពីការបង្កើត ក្រុងកែប និងស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ ក្រុងកែប ។

-បានឃើញអនុក្រឹត្យចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការប្តូរចនាសម្ព័ន្ធរដ្ឋបាល ក្រុងកែប

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួង មហាផ្ទៃ ។

-តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ : ត្រូវបានប្តូររចនាសម្ព័ន្ធរដ្ឋបាល ក្រុងកែប ពីថ្នាក់ស្រុកចំណុះខេត្ត កំពត មកជាថ្នាក់ក្រុងចំណុះក្រសួងមហាផ្ទៃដោយទុកឈ្មោះថា ក្រុងកែប ដដែល។ ទីស្នាក់ការរដ្ឋបាល ក្រុងកែប តាំងនៅសង្កាត់កែប ។

មាត្រា ២ : ក្រុងកែប មានខ័ណ្ឌចំនួនពីរ :

-ខ័ណ្ឌកែបមានសង្កាត់ ចំនួន ពីរ គឺសង្កាត់កែប និង សង្កាត់ព្រៃធំ ។

-ខ័ណ្ឌដំណាក់ចង្អើរមានសង្កាត់ចំនួនបី គឺសង្កាត់អូរក្រសារ សង្កាត់ពងទឹក និង សង្កាត់អង្កោល ។

មាត្រា ៣ : ក្រុងកែប មានផ្ទៃក្រឡាដីគោក ១៣២.១៧ គីឡូម៉ែត្រការ៉េ និង មានព្រំប្រទល់ រដ្ឋបាលដូចខាងក្រោម ៖

- ខាងកើតកាត់យក ឃុំ ភ្នំលាវទី ១ និងឃុំ ភ្នំលាវទី ២ ពីស្រុក កំពង់ត្រាច ។
- ខាងលិច កាត់យកឃុំ អូរក្រសារ ទាំងមូលពីស្រុក កំពត ។
- ខាងជើងទល់និង ឃុំ កូនសត្វស្ថិតនៅក្នុងស្រុក កំពត និង ឃុំ កំពង់ ត្រាច ខាងលិចក្នុង ស្រុក កំពង់ត្រាច ខេត្ត កំពត ។
- ខាងត្បូងទល់និង ដែនសមុទ្រអន្តរជាតិ កម្ពុជា- វៀតណាម ។

មាត្រា ៤ : ត្រូវទុកជានិរាករណ៍ អនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ និង អនុក្រឹត្យលេខ ៣១អនក្រ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩២ ។

មាត្រា ៥ : សហរដ្ឋមន្ត្រី ទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាននិងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកក្រុងកែប ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀង ៗខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៦០ អនក្រ

## ស្តីពីបង្កើតអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរការងារចាំបាច់

## សំរេច

មាត្រា ១ : បង្កើតអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមឱវាទផ្ទាល់របស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានសមត្ថកិច្ចចាត់ចែង និង គ្រប់គ្រងការធ្វើនិតិសម្បទា និងការអភិវឌ្ឍន៍អាកាសយានដ្ឋានក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។